# ការសម្ភាសរបស់អ៊ុំស្រី ចៀន ពៅ

**កៈ អ្នកសម្ភាសឈ្មោះជាង ស៊ីអ៊ាវ** **ខៈ អ្នកទទួលការសម្ភាសឈ្មោះ ចៀន ពៅ**

## ការសង្ខេបប្រវត្តិរបស់អ៊ុំស្រី ចៀន ពៅ

អ៊ុំស្រីចៀន ពៅ មានអាយុ៥៧ ឆ្នាំនៅក្នុងឆ្នាំ២០២០ ភេទស្រី មានទីលំនៅបច្ចុប្បន្ននៅភូមិទួលរកា ឃុំរអាង ស្រុកកំពង់សៀម ខេត្តកំពង់ចាម។

កៈ ចឹងជាដំបូងខ្ញុំអរគុណច្រើនអ៊ុំដែរបានអោយខ្ញុំពិភាក្សាជាមួយអ៊ុំទាក់ទងពីប្រវត្តិរបស់អ៊ុំ?

ខៈ ចាំ!

កៈ ហើយការសម្ភាសទាំងអស់នេះត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU?

ខៈ ចាំ!

កៈ ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរ ដើម្បីទុកអោយកូនចៅជំនាន់ក្រោយពួកគាត់បានស្គាល់ហ្នឹងបានដឹងពីប្រវត្តិឪពុកម្ដាយហ្នឹងដូនតា?

ខៈ ចាំ!

កៈ ជាពិសេសប្រវត្តិដែរខ្ញុំបានសម្ភាសអ៊ុំហ្នឹងខ្ញុំទុកអោយកូនចៅរបស់អ៊ុំបានស្គាល់បានដឹងចឹងហាសណាស់អ៊ុំ?

ខៈ ចាំ!

កៈ បាទចឹងអ៊ុំយល់ព្រមដើម្បីអោយខ្ញុំដាក់ការសម្ភាសមួយហ្នឹងទៅក្នុងវេបសាយសាលាទេអ៊ុំអត់អីទេណោះអ៊ុំណោះ?

ខៈ ចាំ!

ក៖ បាទអ៊ុំ!

ខ៖ ធ្វើម៉េចបើសម្ភាសហើយ!

ក៖ បាទ!

ខ៖ ធ្វើអីទេ។

ក៖ ចឹងសំរាប់ខ្ញុំជាអ្នកសម្ភាសអ៊ុំខ្ញុំមានឈ្មោះថាជាង ស៊ីអារហើយថ្ងៃខែដែរខ្ញុំសម្ភាសអ៊ុំគឺនៅថ្ងៃទី២៧ខែ៧ឆ្នាំ២០២០ ហើយការសម្ភាសទាំងអស់ហ្នឹងគឺធ្វើឡើងនៅភូមិទូលរកា ឃុំរអាង ស្រុកកំពង់សៀម ខេត្តកំពង់ចាម?

ខ៖ ចាំ!

ក៖ ចឹងសំរាប់អ៊ុំឈ្មោះពេញរបស់អ៊ុំតាមបញ្ជីជាតិហាសឈ្មោះអីគេអ៊ុំ?

ខ៖ ឈ្មោះចៀនពៅ។

ក៖ ចៀនពៅអ៊ុំ?

ខ៖ ចាំ!

ក៖ ចុះមានឈ្មោះហៅក្រៅអត់អ៊ុំ?

ខ៖ អត់មានទេមានតែឈ្មោះហ្នឹងដដែរហ្នឹង!

ក៖ អូ៎ចុះកាលពីក្មេងធ្លាប់មានឪពុកម្ដាយរឺមួយក៏បងប្អូនសាច់ញ្ញាតិអីហៅឈ្មោះអ៊ុំអីលេង?

ខ៖ ហៅតែចឹងដដែរហ្នឹងគ្មានហៅលេងអីទេ។

ក៖ អូ៎ហៅតែពៅចឹងម៉ងហោស?

ខ៖ ចាំ!

ក៖ អូ៎បាទអ៊ុំចុះអើសព្វថ្ងៃអ៊ុំអាយុប៉ុន្មានទៅអ៊ុំ?

ខ៖ ហាប្រាំពីរ។

កៈ ហាសិបប្រាំពីរឆ្នាំ?

ខៈ ចា៎!

កៈ ប្អូនខ្ញុំបីប្ងូនឆ្នាំអ៊ុំចុះអ៊ុំកើតនៅថ្ងៃខែឆ្នាំណាអ៊ុំចាំទេ?

ខៈ អត់ចាំសោះ។

កៈ ឆ្នាំក៏អ៊ុំអត់ចាំដែរ?

ខៈ ចា៎!

កៈ អ៊ុំបាទអ៊ុំអើចឹងអើអ៊ុំឆ្នាំច័ន្ទគតិជូត ឆ្លូវ ខាល ថោះអ៊ុំឆ្នាំអីគេអ៊ុំ?

ខៈ អត់ដឹងឆ្នាំអីទេបើទាល់តែមើលសៀវភៅបានដឹង។

កៈ ជូត ឆ្លូវ ខាល ថោះ រោង ម្សាញ់ហាស?

ខៈ អ៊ុំខ្ញុំឆ្នាំហោស?

កៈ បាទអ៊ុំ!

ខៈ ឆ្នាំរោង។

កៈ ឆ្នាំរោងណោះអ៊ុំណោះ?

ខៈ ចា៎!

កៈ អ៊ុំបាទអ៊ុំចុះអើអ៊ុំស្រុកកំណើតដែរអ៊ុំកើតម៉ងអ៊ុំកើតនៅណាអ៊ុំ?

ខៈ នៅហ្នឹងតែម៉ង។

កៈ នៅទួលរកាហ្នឹងម៉ងហោស

ខៈ ចា៎!

កៈ អ៊ុំបាទអ៊ុំបាទចុះអ៊ុំមានបងប្អូនបង្កើតចំនួនប៉ុន្មាននាក់ទៅអ៊ុំ?

ខ៖ មានបងប្អូនបង្កើតមានក្រោយមានមុន។

ក៖ អូ៎មានក្រោយមានមុន?

ខ៖ ចា៎!

ក៖ ចឹងមានន័យថាឪពុកម្ដាយអ៊ុំមានកូនពីរដង?

ខ៖ ម៉ែអើម៉ែខ្ញុំហ្នឹងយកទាខ្ញុំហ្នឹងកូនក្រោយចឹងហាសយកកូនក្រោយ។

ក៖ អូ៎!

ខ៖ រួចទាខ្ញុំមានប្រពន្ធទៅស្លាប់ទៅយកម៉ែខ្ញុំអីចឹងហាស!

ក៖ អូ៎បាទអ៊ុំបាទ!

ខ៖ ចា៎!

ក៖ ចុះអសរុបទាំងអស់ម៉ងប៉ុន្មាននាក់អ៊ុំ?

ខ៖ សរុបទាំងមុនទាំងក្រោយហ្នឹង?

ក៖ បាទ!

ខ៖ សរុបទាំងមុនទាំងក្រោយមើលខាងនោះច្រើនហាស ប្រាំអីណោះប្រាំម៉ែខ្ញុំណោះប្រាំដៃរដប់។

ក៖ ចុម..?

ខ៖ រួចប្ដីគាត់មុនពីរទៀត។

ក៖ ច្រើនៗហាសណោះអ៊ុំណោះ?

ខ៖ ចា៎កូនពីរបីសំបុកហើយមិនច្រើន។

ក៖ បាទអ៊ុំបាទ!

ខ៖ ចាំ!

ក៖ ចុះអ៊ុំអាចប្រាប់ឈ្មោះពួកគាត់បានទេដូចជាអ៊ុំប្រាប់តែខាងជំនាន់ជាមួយអ៊ុំក៏បានដែរប្រាំកូនក្រោយហ្នឹងហាស?

ខ៖ ក្រោយហោសកូនក្រោយហោស?

ក៖ បាទអ៊ុំ!

ខ៖ និយាយប្រាប់តែកូនសំបុកម៉ែខ្ញុំម៉ងទៅ។

ក៖ បាទអ៊ុំបាទ!

ខ៖ ឈ្មោះតាពេជ្រ យាយស័ន ញ៉ រួចខ្ញុំឈ្មោះពៅហ្នឹង រួចឈ្មោះរ៉ា។

ក៖ អូ៎!

ខ៖ ប្រាំ។

ក៖ បាទ!

ខ៖ ចាំ!

ក៖ រួចចុះអើបងធំតាពេជ្រគាត់ធ្វើអីគេទៅអ៊ុំហើយគាត់នៅណាទៅ?

ខ៖ ធ្វើការនៅភ្នំពេញធ្វើសន្តិសុខនៅយាមផ្ទះគេ។

ក៖ អូ៎!

ខ៖ ចាំ!

ក៖ រួចចុះបន្ទាប់មក?

ខ៖ បន្ទាប់មកនៅស្រីនៅផ្ទះ។

ក៖ អូ៎ប៉ុន្តែនៅហ្នឹងទេ?

ខ៖ នៅណោះនៅភូមិមុខហោស!

ក៖ អូ៎!

ខ៖ ភូមិរអាងលើគេហៅភូមិរអាងលើ។

ក៖ អូ៎បាទអ៊ុំ!

ខ៖ ចា៎!

ក៖ បន្ទាប់មកទៀតអ៊ុំ?

ខ៖ ចា៎ខ្ញុំនៅហ្នឹងនៅទួលរកាហ្នឹង!

ក៖ អូ៎អ៊ុំចុះកូនទីបួន?

ខ៖ បងខ្ញុំមួយទៀតនៅម្លិចប៉ុនងាប់ហើយ!

ក៖ អូ៎!

ខ៖ ចា៎!

ក៖ ប្រាំនាក់ប៉ុនស្លាប់មួយណោះអ៊ុំណោះ?

ខ៖ ចា៎រួចទៅបានមកខ្ញុំហ្នឹង!

ក៖ ហើយពៅគេ?

ខ៖ នៅព្រែកសង្កែ។

ក៖ អូ៎គាត់ធ្វើអីគេនៅណុងអ៊ុំ?

ខ៖ នៅរកស៊ីគាត់រកឡានរកអីនៅធ្វើចំការធ្វើអីតិចតួចហ្នឹងហាស!

ក៖ អូ៎!

ខ៖ ចា៎!

កៈ បាទអ៊ុំបាទចុះអ៊ុំគិតថាអ៊ុំធ្លាប់មានជាអនុស្សាវរីយ៍ជាមួយបងប្អូនអ៊ុំកាលនៅក្មេងអត់អ៊ុំ លក្ខណៈទៅធ្វើស្រែដែរអ៊ុំចងចាំរឺធ្វើចំការធ្វើអីមួយ?

ខៈ មានដែរធ្វើប៉ុនកាលពីខ្ញុំនៅតូចៗណុងខ្ញុំនៅជំនាន់អាពតណុងពេលធំមកបែកគ្នាអស់ហើយ!

កៈ អូ៎ចឹងហោសអ៊ុំ?

ខៈ ចា៎ធំមកគេតែបងៗគេមានប្ដីមានប្រពន្ធចឹងគេបែកគ្នាចឹងរួចខ្ញុំនៅរៀនចឹងមានប្ដីក្រោយគេនៅហ្នឹងរួចគេដឹងគេបែកគ្នាអស់ហើយបងប្អូនប៉ុន្តែជំនាន់អាពតអីចឹងមានអាប្អូនពៅមួយនោះទៅកុមារអីចឹងហាស!

កៈ អូ៎!

ខៈ គេបង្អត់បាយបង្អត់អីចឹងទៅខ្ញុំបានបាយអីតិចតួចចឹងទៅអោយប្អូនស៊ីមិនហ៊ានស៊ីទេខ្លួនឯងហោស អាណិតប្អូនៗនៅតូចអីចឹងហាស!

កៈ បាទអ៊ុំបាទ!

ខៈ កាលជំនាន់អាពតវេទនាស៊ីបាយ។

កៈ ចុះអើមើលអ៊ុំទាន់ជំនាន់ណាជំនាន់លុនណុល?

ខៈ ចា៎លុនណុលកាលណុងគេបន្តក់គ្រាប់បែកយន្តហោះគេទំលាក់ហោស!

កៈ បាញ់គ្រាប់ផ្លោងហ្នឹងហី?

ខៈ ចា៎ហ្នឹងហើយបាញ់គ្រាប់ផ្លោងណុងរត់ចូលត្រែងស៊ីបាយក្នុងរូងអីហ្នឹង!

កៈ ប៉ុន្តែយើងនៅណាយើងនៅហ្នឹងដដែរ?

ខៈ នៅហ្នឹងដែរខ្ញុំ។

កៈ អូ៎!

ខៈ ចា៎!

ក៖ ប៉ុន្តែមានគ្រាប់ផ្លោងបន្ទក់ត្រូវផ្ទះត្រូវអីអត់?

ខ៖ មានហាសមានត្រូវគោទៅយន្តហោះណុងបាញ់អាទ្រុងជ្រូកបាញ់ណុងបាញ់គោបាញ់អីហ្នឹងមានមនុស្សដើរអីចឹងទៅ ដើរទៅធ្វើប្រាំងអីចឹងទៅយន្តហោះមើលពីលើមកឃើញយើងតាមបាញ់យើងរត់ចូលព្រៃហើយ តាមបាញ់រួចចេះតែរត់គេចពីវាទៅយើងរត់រួចទៅបាញ់ត្រូវគោត្រូវអីចឹងហាសហូរហៃចឹងមក។

ក៖ អូ៎!

ខ៖ ជំនាន់ណុងចាំរួចពេលចឹងទៅមកចឹងទៅមកចិតប្រាំហ្នឹងរត់ទៅនៅថ្លុកត្រែងទៅថ្លុកត្រែងល្អៀកហ្នឹងហាស!

ក៖ បាទអ៊ុំ!

ខ៖ នៅលើភ្នំកោះខ្ទីងណុងហូរហៃមកវេទនាចឹងនៅពេលហ៉ៅទៅនៅចិតប្រាំណុង ចិតប្រាំមកវិញហើយចិតបីទៅ។

ក៖ បាទអ៊ុំបាទ!

ខ៖ ចាំដល់ពេលចិតប្រាំយើងមកវិញមកនៅហ្នឹងហាស នៅហ្នឹងចិតចូលចិតប្រាំចិតប្រាំមួយចិតប្រាំពីរហ្នឹងចិតប្រាំបីអូ៎ចឹងហើយចិតប្រាំពីរចិតប្រាំបីចិតប្រាំបួនហ្នឹងនៅហ្នឹងអាពតធ្វើបាបនៅហ្នឹង!

ក៖ អូ៎!

ខ៖ បាយទឹករលិបចំណីហ្នឹងវេទនានៅហ្នឹង!

ក៖ អូ៎!

ខ៖ ចាំ!

ក៖ ចុះអើកាលជំនាន់លុនណុលណុងដូចជាពេលណុងយើងរកស៊ីអីទៅអ៊ុំធ្វើស្រែចំការដែររឺមួយក៏ម៉េច?

ខ៖ ចាំធ្វើស្រែចំការ។

កៈ អ៊ូរួចចុះអើយើងមានត្រង់សេមានអីដែរតើ?

ខៈ មានបាយដាំក្នុងត្រង់សេហ្នឹងស៊ីក៏ក្នុងហ្នឹងដេកក៏ក្នុងហ្នឹងកាលណុងវាបន្តក់ខ្លាំងហាស ណាស់!

កៈ បាទអ៊ុំ!

ខៈ ចាំទាំងយប់ទាំងថ្ងៃកាំភ្លើងធំបន្តក់ពីភ្នំមក។

កៈ ប៉ុន្តែយើងអត់ដែរធ្វើត្រង់សេនៅក្រោមផ្ទះណាហី?

ខៈ ធ្វើធ្វើនៅក្រោមផ្ទះយប់ចឹងទៅដេកក្រោមផ្ទះទៅ ថ្ងៃនៅកណ្ដាលវាលទៅអាហ្នឹងវាមាំជាង អាត្រង់សេនៅក្រោមផ្ទះហ្នឹងយើងគ្រាន់តែរាប់បណ្ដើសរៀបអីចឹង យើងចាក់ដីទៅគ្របចឹងទៅ សំរាប់ពេលយប់ដេក។

កៈ អ៊ូ!

ខៈ ចាំ!

កៈ បាទអ៊ុំពិបាកចឹងហាសណេះអ៊ុំ?

ខៈ ពិបាកអ៊ូនិយាយពីរឿងពិបាកពិបាកមែនទែនមួយជំនាន់អាពតណុងស្ងោរគេលប់ចេកស៊ីខ្ញុំទៅ ស្ងួង គេអោយតែកងចល័តស្ងួងថ្នាក់ដាក់អំបិលតាមហោប៉ាវអាវចាប់ក្ដាមកូនក្ដាមហែកស៊ី ជាមួយស្លឹកផ្ទឹងអីក៏ធ្លាប់ដែរ។

កៈ ខ្ញុំអត់ដែរទេ។

ខៈ អត់ដែរទេហោសខ្ញុំទៅចឹងជំនាន់អាពតណុងវេទនាណាស់ថាអើយវេទនាមែនទែន។

កៈ អ៊ូ!

ខៈ ចាំ!

កៈ ប៉ុន្តែគេជំលាសអ៊ុំទៅណាដំបូង?

ខៈ មុនដំបូងកាលចិតបីហ្នឹងគេជំលាសទៅនៅ..។

កៈ ល្មៀក?

ខៈ ល្មៀកហ្នឹងភ្ញុំហ្នឹងកោះខ្ទីងហ្នឹងដល់ពេលចិតប្រាំយើងមកហ្នឹងវិញហ្នឹងចូលអាពតហ្នឹង!

កៈ ចុះចូលអាពតគេកៀរយើងទៅណាទៅ?

ខៈ ដល់ពេលមកចូលអាពតអត់បានគៀងយើងទៅណាទេនៅហ្នឹងតែម៉ង។

កៈ គេអោយនៅហ្នឹងហោស?

ខៈ ចាំយើងអ្នកស្រុកភូមិហ្នឹងគេអត់មានគៀងទេប៉ុន្តែយើងនៅហ្នឹងក៏វេទនាដែរ អត់មានបាយ មានទឹកអីហូបចឹងបបរមួយវែកមកចឹងលាយពោតក្រហមប៉ុនៗមេដៃទៅបបរីកមួយវែកចឹង ទៅស៊ីទៅប៉ុណ្ណឹងទៅ ឃ្លានខ្លាំងស្មោរគល់ចេកស្មោរអីស៊ីទៅ។

កៈ អូ៎!

ខៈ ទ៊ាខ្ញុំស្មោរតាំងពីប្រលិតឡើងហោសដាក់លាយជាមួយបបរមានអីហូបហោសជំនាន់អាពត ហោសវេទនា។

កៈ ចេះអត់អីដែរអ៊ុំ?

ខៈ ចាំយើងចេះតែទ្រាំទៅអត់ឃ្លានខ្លះអត់ខ្លះទៅធ្វើម៉េច។

កៈ កាលជំនាន់ណុងហូបបបររឺហូបបាយ?

ខៈ បបររហូតបបរលាយគ្រាប់ពោតក្រហមទៀតហាសមែនត្រឹមបបរសុទ្ធទេ រួចមួយវែកសំល ទេចែចុះជំនាន់អាពតហោស!

កៈ យើងមិនរាគយើងអីហើយណោះអ៊ុំ?

ខៈ អើរាគទៅណាលោកអើយគេប្រើយ៉ាងនេះមិនដូចសម័យឥឡូវគ្រប់គ្រាន់ពេញលេញ ហើយមានជំងឺឈឺស្កាត់អីជំនាន់នោះគ្មានមិនសូវមានជំងឺទេ។

កៈ ប៉ុន្តែគ្រាន់ថាយើងហេវយើងអត់សូវមានកំលាំង?

ខៈ ចាំហេវ។

កៈ អុំបាទអុំរួចចុះអើទាក់ទងពីចឹងអើអុំគិតថាការងារយើង យើងធ្វើការងារអីគេខ្លះទៅពេលប៉ុលពតហោស?

ខៈ ការងារវែកដីគេអោយខ្ញុំស្ទូងគេអោយខ្ញុំវែកដីវែកដីនៅទំនប់កែប្រែត្រួយចេកនោះរួចទៅរួចវែកដីហ្នឹងទៅគេអោយខ្ញុំមកស្ទូង ច្រូតស្រូវសព្វទាំងអស់រឿងស្ទូងដកអីសព្វខែច្រូតច្រូតខែស្ទូងស្ទូងគេផុតពីស្ទូងទៅគេអោយយើងទៅវែកដីទៅចឹងមកហូរហែចឹងមក។

កៈ អុំបាទអុំបាទចុះអើភាគច្រើនការងារគេធ្វើប៉ុន្មានម៉ោងអុំ?

ខៈ អើគ្មានពេលម៉ោងទេជំនាន់អាពតហោស អត់មានម៉ោងមានពេលអីទេយប់ក៏ធ្វើដែរ។

កៈ អុំ

ខៈ យប់បើយប់ក៏ធ្វើការថ្ងៃក៏ធ្វើការដែរមានម៉ោងមានពេលអីណាបើយើងមិនធ្វើគេមិនវ៉ៃចោល។

កៈ អុំបាទ!

ខៈ ចាំ!

កៈ ចុះយើងឈឺយើងធ្វើម៉េចគេមានថ្នាំមានអីអោយ?

ខៈ ឈឺគេអោយយើងទៅពេទ្យទៅអាថ្នាំគេគេផលិតឬសឈើឬសអីហ្នឹងគេបុកគេលុញមកអោយយើងផឹកចឹងទៅ។

កៈ ដូចអាចម៍ទន្សាយហ្នឹង?

ខៈ ហ្នឹងអាថ្នាំអាចម៍ទន្សាយហ្នឹងទៅ។

កៈ អុំបាទ!

ខៈ ថ្នាំចឹង។

កៈ បាទអុំបាទ!

ខៈ ចាំ!

កៈ រួចចុះអើទាក់ទងពីយាយគេអត់ចឹងបីឆ្នាំជាងគឺយើងនៅហ្នឹងម៉ងគេអត់ជំលាសយើងទៅណាទេ?

ខៈ នៅហ្នឹងរហូតអត់មានជំលាសទៅណាទេគ្រាន់តែវាវេទនារឿងបាយរឿងទឹកចឹងហាស!

កៈ បាទ!

ខៈ ចាំ!

កៈ ហើយធ្វើការធ្ងន់ៗចឹងហាសណេះ?

ខៈ ហ្នឹងធ្វើការធ្ងន់ៗហ្នឹង!

កៈ រួចចុះបងប្អូនយើងឪពុកម្ដាយយើង?

ខៈ ឪពុកម្ដាយខ្ញុំនៅហ្នឹងដែរប៉ុនគាត់គេមិនអោយជុំគ្នាណា ម្ដាយនៅផ្សេងទៅឪពុកនៅផ្សេងគាត់នៅធ្វើការផ្សេងទៅកូននៅធ្វើការផ្សេងទៅខុសពីគ្នាចឹងអត់មាននៅជុំគ្នាណា។

កៈ អូ៎!

ខៈ ចាំ!

កៈ យើងនៅបែកគ្នាដែរហោស?

ខៈ ចាំបែកគ្នា..។

កៈ ប៉ុន្តែគ្រាន់នៅក្នុងស្រុកភូមិតែមួយ?

ខៈ គ្រាន់នៅក្នុងភូមិតែមួយហ្នឹង!

កៈ តែចុះបងប្អូនៗចេញ?

ខៈ បងខ្ញុំគេអោយទៅអាខ្លះក៏គេអោយទៅចល័តទៅអីណាផ្សេងទៅ អើម៉ែខ្ញុំទៅផ្សេងទៅទាខ្ញុំទៅផ្សេងទៅយប់ក៏មិនបានដេកជុំគ្នាដែរយើងទៅដេកនៅអីចល័តណុង។

កៈ អូ៎!

ខ៖ បងទៅអីណោះផ្សេងទៅគ្រាន់គេដាក់មួយពួកៗចឹងតើណាស់មួយក្រុមប្រុសផ្សេងចឹងទៅប្រុសចឹងទៅទៅខាងណាគេចែកមុខព្រួញចឹង។

ក៖ អូ៎!

ខ៖ ទៅឆ្ងាយៗចឹងទៅ។

ក៖ ប៉ុន្តែគេមានអោយយើងមកលេងគ្នាអត់អ៊ុំមកលេង?

ខ៖ យើងគេមិនអោយយើងមកលេងទេមើលគ្រាន់តែថាយើងនឹកម្ដាយខ្លាំងលួចរត់មកចឹងទៅមកមួយភ្លែតចឹងទៅទៅវិញទៅកុំអោយគេដឹងចឹងបាន បើថាគេអោយយើងមកលេងហោសគេមិនអោយមកទេ។

ក៖ រួចចុះបើគេដឹងម៉េចទៅអ៊ុំ?

ខ៖ គេវៃចោលណុងហាស!

ក៖ អូ៎!

ខ៖ ចា៎!

ក៖ អ៊ុំធ្លាប់មកដែរហោស?

ខ៖ ធ្លាប់មកដែរ។

ក៖ ចុះអ៊ុំរឿងម្ហូបអាហារវិញអ៊ុំធ្លាប់អើដូចជាលួចជីកក្ដួចជីកដំឡូងអីហ្វប?

ខ៖ លួចលួចកាយដំឡូងអីចឹងទៅលួចកាចពោតអីគេលួចផ្លែចេកអី។

ក៖ អូ៎!

ខ៖ បើឃ្លានលួច។

ក៖ ប៉ុន្តែគេអត់ដឹងទេណោះ?

ខ៖ ចា៎លួចមិនអោយគេដឹងទេលួចអោយគេដឹងគេវៃចោល។

កៈ អ្នកភូមិហ្នឹងធ្វើចឹងដែរ?

ខៈ ដូចតែគ្នាហ្នឹង!

កៈ ឃ្លានហើយណេះអ៊ុំណេះ?

ខៈ ចាំឃ្លាន។

កៈ អូ៎បាទអ៊ុំបាទ!

ខៈ ទាំងអស់តែគ្នាហ្នឹង!

កៈ ចឹងមានន័យថាយើងអទ់ទៅណាទេចឹងមានន័យថាបើយើងដាច់ពីប៉ុលពតមកយើងនៅផ្ទះយើងវិញណេះ?

ខៈ ចាំនៅស្រុកយើងវិញ។

កៈ យើងមិនចាំបាច់ដំរទៅណាឆ្ងាយ?

ខៈ អត់ផង។

កៈ អូ៎ល្អ!

ខៈ ចាំ!

កៈ រួចចុះនៅពេលដែរយើងចាប់ផ្ដើមដាច់ប៉ុលពតយើងចាប់ផ្ដើមធ្វើស្រែរួមណេះអ៊ុំណេះ?

ខៈ ធ្វើស្រែរួមដំបូងហោសមួយឆ្នាំដំបូងធ្វើស្រែរួមដល់ពេលមកក្រោយទៀតគេចែកតាមគ្រួសារចឹងទៅ គ្រួសារមានច្រើនគេចែកបានក្រែលចឹងទៅដីស្រែប្រាំងហ្នឹងបើគ្រួសារណាតិចបានតិចចឹងទៅ។

កៈ អូ៎!

ខៈ ចាំ!

កៈ បាទអ៊ុំតែអ៊ុំកាលណុងមានច្រើនណេះអ៊ុំណេះ?

ខ៖ មិនច្រើនទេគ្នាខ្ញុំបន្តិចដែរ។

ក៖ បងប្អូនប្រាំនាក់?

ខ៖ ចែកតាមគ្រួសារហាសប្រាំនាក់មិននៅជុំគ្នាណាគេមានប្តីមានប្រពន្ធទៅនៅតែប្អូនខ្ញុំមួយ ហើយខ្ញុំមួយហើយម៉ែឪហ្នឹងពីរនាក់ហ្នឹងរបបបានតែបួនណុង។

ក៖ អូ៎!

ខ៖ ចា៎!

ក៖ បានតិចដែរចឹង?

ខ៖ តិចចឹងទៅដីយើងនៅក្រោយៗនៅសេសសល់ពីគេចែកអីចឹង កាប់គាស់រាស់រានអីទៅធ្វើ កាយអីចឹងទៅយកមកធ្វើប្រាំងផ្សំទុកស្រូវហ្នឹងហូបចឹងទៅ។

ក៖ អូ៎!

ខ៖ ចា៎!

ក៖ ប៉ុន្តែកាលអ៊ុំការហ្នឹងការពេលណា?

ខ៖ អើយខ្ញុំការមកប៉ែត្រជាងហើយហ្នឹងខ្ញុំការប៉ែត្រពីរ។

ក៖ ការប៉ែត្រពីរហោសអ៊ុំ?

ខ៖ ចា៎!

ក៖ អូ៎ប៉ុន្តែនៅពេលអ៊ុំការហ្នឹងគិតថាពិបាកអត់?

ខ៖ ពិបាកដែរណុងហាសកាលជំនាន់ណុងហាស ខ្ញុំការហ្នឹងក្រដែរគេចងដៃអង្គរស្រូវ។

ក៖ អូ៎!

ខ៖ ចា៎!

កៈ ប៉ុន្តែគេការគេការដូចតែយើងដែរតើហីអ៊ុំហោសរឺក៏ខុសពីយើងកាលជំនាន់ណុងមានបុកល័ក្ខបុកអីដូចយើងដែរតើហោស?

ខៈ មានដែរប៉ុន្តែវាមិនពេញលេញដូចមកឥឡូវគេមានគ្រប់គ្រាន់ចឹងទេ។

កៈ អូ៎!

ខៈ កាលនៅណុងវាខ្សត់ខ្សោយតាំងពីខោអាវស្លៀកពាក់ឡើង។

កៈ បាទអ៊ុំបាទ!

ខៈ មានតែតិចតួចចឹងស្លៀកមែនដូចឥឡូវគេពេញលេញសំបូរហូរហៀខោអាវគេគ្រប់ម៉ាកហោស!

កៈ អូ៎បាទអ៊ុំបាទ!

ខៈ ចា៎!

កៈ ចុះអើអ៊ុំគិតថាពេលណាដែរយើងចាប់ផ្ដើមយើងសប្បាយហាសអ៊ុំយើងគិតថាអូ៎លែងមានសង្គ្រាមលែងមានអីទៀត ដូចជានៅឆ្នាំនៅឧន្ទាក់រឺមួយក៏ម៉េចអ៊ុំ?

ខៈ ឆ្នាំឧន្ទាក់ណុងមិនទាន់សប្បាយទេ។

កៈ ឆ្នាំកៅបីមែនទេអ៊ុំឧន្ទាក់?

ខៈ កៅបីណុងហើយនៅមួយជំនាន់ខ្ញុំការណុងនៅមានអាពតនៅឡើយណុងប៉ែត្រពីរប៉ែត្របីប៉ែត្របួន ប៉ែត្រប្រាំហ្នឹងខ្ញុំនៅគេការរួចគេចាប់ប្ដីខ្ញុំទៅប្រដាត់ប្រាភីងទៅធ្វើកប្រាំនៅអីណាៗណោះរត់ចង់ងាប់ចង់រស់ទៅចោលកូនចោលប្រពន្ធនៅខ្ញុំកូនតូចហើយមានពោះធំមួយទៀតគេចាប់ប្ដីទៅខែទឹកចាប់ទៅរត់ប្រដាត់ប្រភីងនឹកថាមកចឹងហើយគេយកតែយើងទៅកប្រាំអីចឹងទៀតហ្នឹងហាស!

កៈ បាទអ៊ុំបាទ!

ខៈ ចេះតែរត់អីខ្លះទៅចា៎!

កៈ រួចចុះអ៊ុំគិតថាអើចឹងលីថាឆ្នាំប៉ៃត្រជាងហ្នឹងដូចជាគេចាប់យកធ្វើទាហ៊ានច្រើនហោសអ៊ុំហោស?

ខៈ ចាប់ហ្នឹងហាសចាប់ធ្វើទាហ៊ានហ្នឹងហាសអាឆ្នាំប៉ៃត្រជាងហ្នឹងហាសប្ដីខ្ញុំអីក៏គេចាប់ដែរ។

កៈ ចឹងមែនតែប្ដីអ៊ុំទេគេចាប់គ្រប់គ្នា?

ខៈ ចាំគេចាប់គ្រប់គ្នាហ្នឹងហាស ខ្លះគេរត់គេចទៅអាខ្លះក៏គេរត់មិនរួចទៅទៅ។

កៈ អ៊ូ!

ខៈ ចាំធ្វើទាហ៊ាន។

កៈ រួចចុះពេលណាដែរអ៊ុំគិតថាអើលែងមានសង្គ្រាមហើយដូចជាមានសប្បាសហាសនៅឆ្នាំប៉ុន្មានទៅពីរពាន់ជាងរឺមួយក៏ម៉េចអ៊ុំ ដែរអ៊ុំគិតថាអ៊ូអ៊ុំមានអារម្មណ៍រៀងធូរធារហើយលែងមានបញ្ហាអីទៀតហើយ?

ខៈ អើយមិនធូរធារទេឥឡូវហ្នឹងក៏នៅតែវេទនាដែរហ្នឹង!

កៈ ចឹងហោសអ៊ុំ?

ខៈ ចាំ!

កៈ អ៊ូបាទអ៊ុំចុះអ៊ុំគិតថាអើឪពុករបស់អ៊ុំឈ្មោះអីគេអ៊ុំ?

ខៈ ឪពុកខ្ញុំឈ្មោះចៀន។

កៈ ឈ្មោះអីគេចៀនទៅ?

ខៈ ឡោកចៀន។

កៈ ឡៅចៀន?

ខៈ ឡោក។

កៈ ឡោកហោសអ៊ុំ?

ខ៖ ចា៎!

ក៖ អ៎ូឡោកចៀនរួចចុះម្ដាយរបស់អ៊ុំ?

ខ៖ ម៉ែឈ្មោះម៉ែខ្ញុំហោសស សុក។

ក៖ ស សុកអ៎ូប៉ុន្តែគាត់អ្នកស្រុកនៅណានៅហ្នឹងតើហីអ៊ុំណេះ?

ខ៖ អ្នកស្រុកគាត់ដំបូងម៉ែខ្ញុំនៅស្រុកគាត់ណោះស្រុកច្រានហោសគាត់មកយកទ៊ាខ្ញុំនៅហ្នឹង!

ក៖ អ៎ូ!

ខ៖ ចា៎!

ក៖ តែគាត់អ្នកស្រុកកំពង់ចាមទាំងអស់គ្នាណោះអ៊ុំ?

ខ៖ ចា៎!

ក៖ ចុះអ៊ុំគិតថាចឹងសំរាប់ដូចជាឪពុករបស់អ៊ុំកាលគាត់នៅរស់គាត់ស្លាប់ហើយហី?

ខ៖ ស្លាប់ហើយគាត់ស្លាប់ហើយ!

ក៖ កាលគាត់នៅរស់គាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិត ចិញ្ចឹមកូនចៅចិញ្ចឹមក្រុមគ្រួសារ?

ខ៖ ធ្វើស្រែធ្វើប្រាំងហ្នឹងចិញ្ចឹមគោចិញ្ចឹមពពែហ្នឹងទាំងអស់ហ្នឹងគាត់មានធ្វើអីទេទ៊ាខ្ញុំគាត់ធ្វើតែចំការ។

ក៖ អ៎ូ!

ខ៖ ចា៎!

ក៖ គាត់ស្លូតរឺមួយក៏កាចអ៊ុំ?

ខ៖ គាត់ស្លូត។

ក៖ អ៎ូគាត់ស្លូតដែរហោស?

ខ៖ ចាំ!

ក៖ រួចចុះម្ដាយរបស់អ៊ុំគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតចិញ្ចឹមកូនចៅ?

ខ៖ ម៉ែខ្ញុំក៏ធ្វើចឹងដែរធ្វើប្រាំងធ្វើស្រែចឹងដូចគ្នា។

ក៖ អូ៎!

ខ៖ ចាំ!

ក៖ គាត់កាចអត់អ៊ុំ?

ខ៖ ម៉ែខ្ញុំគាត់ទ្រុងកាចបន្តិច។

ក៖ អូ៎ចឹងហោសអ៊ុំ?

ខ៖ ចាំ!

ក៖ អ៊ុំធ្លាប់មានជាអនុស្សាវរីយ៍ដែរអ៊ុំដូចជាបានធ្វើអីគេខ្លះជាមួយឪពុកម្ដាយអ៊ុំកាលនៅក្មេងៗធ្លាប់មានជាអនុស្សាវរីយ៍ជាមួយពួកគាត់អត់ ដូចជាអ៊ុំចងចាំធ្វើស្រែធ្វើចំការអីចឹងហាសណាស់អ៊ុំ?

ខ៖ ចាំខ្ញុំកាលពីនោះមកជំនាន់អាពតជំនាន់ណុងដឹងក្ដីមកមិនទាន់មានអនុស្សាវរីយ៍ មានតែអនុស្សាវរីយ៍រត់គេចពីគ្រាប់បែកគ្រាប់ផ្លោងហ្នឹង អើពេលធ្វើស្រែធ្វើប្រាំងហ្នឹងមិនទាន់មានទេព្រោះខ្ញុំនៅតូច។

ក៖ អូ៎!

ខ៖ ចាំ!

ក៖ បាទអ៊ុំ!

ខ៖ នៅតូចកាលពីរត់គ្រាប់ផ្លោងខ្ញុំនៅប៉ុននេះហ្នឹង!

ក៖ អូ៎!

ខ៖ ចា៎រត់ទៅហ្នឹង!

ក៖ បាទអ៊ុំបាទ!

ខ៖ តាំងពីចិតមួយចិតពីរណុងនៅតូចណុងចា៎មិនទាន់បានធ្វើមានធំអីណាព្រោះក្មេងនៅតូច នៅរត់លេងនៅឡើយ។

ក៖ អូ៎ប៉ុន្តែអើម្តាយឪពុករបស់អ៊ុំគាត់ស្លាប់នៅពេលណាអ៊ុំ?

ខ៖ ម៉ែខ្ញុំទើបស្លាប់ទើបខូចប៉ុន្មានឆ្នាំនេះហ្នឹង!

ក៖ អូ៎ប៉ុន្តែឪពុក?

ខ៖ ឪពុកខ្ញុំក៏គាត់ទើបខូចមកដាច់អាពតហ្នឹងហើយបានគាត់ខូចម្ភៃឆ្នាំជាងហើយ!

ក៖ អូ៎!

ខ៖ ចា៎!

ក៖ បាទអ៊ុំបាទចុះអើឪពុកគាត់ធ្លាប់ប្រាប់ពីប្រវត្តិកាលគាត់នៅក្មេងទៅអ៊ុំអត់ពេលគាត់នៅរស់ ហាស ថាពីក្មេងគាត់នៅរស់គាត់យកម្តាយរបស់អ៊ុំគាត់ធ្វើអីគេខ្លះគាត់ធ្លាប់និយាយអត់?

ខ៖ និយាយគាត់យកម៉ែខ្ញុំគាត់ធ្វើប្រាំងដែរគាត់ធ្វើចំការគាត់ធ្វើឡថ្នាំចឹងហាស!

ក៖ អូ៎បាទអ៊ុំបាទ!

ខ៖ ចា៎!

ក៖ រួចចុះឪពុករបស់អ៊ុំគាត់ធ្លាប់ប្រាប់និយាយអីទៅអ៊ុំអត់?

ខ៖ និយាយគាត់មិនសូវអ្នកនិយាយទេព្រោះគាត់មិនសូវអ្នកមាត់ដែរ។

ក៖ អូ៎!

ខ៖ ចា៎!

ក៖ គាត់អត់សូវជាចេះនិយាយស្តីទេណោះអ៊ុំ?

ខ៖ ចា៎!

ក៖ អូ៎បាទអ៊ុំបាទចុះអើយាយតាខាងឪពុកអ៊ុំស្គាល់ឈ្មោះគាត់អត់?

ខ៖ ស្គាល់។

ក៖ យាយតាខាងឪពុកឈ្មោះអីគេអ៊ុំ?

ខ៖ ឈ្មោះឡេក។

ក៖ តាឡេកហោស?

ខ៖ តាឡេ យាយគុណ។

ក៖ យាយគុណ ចំយាយតាខាងម្ដាយ?

ខ៖ យាយតាខាងម្ដាយឈ្មោះតាឈ្មោះតាស យាយហេង។

ក៖ តាស យាយហេងអូ៎ចឹងគាត់អ្នកនៅស្រុកហ្នឹងដែរណោះអ៊ុំណោះគាត់អ្នកនៅស្រុកហ្នឹងដែរតើហី?

ខ៖ ចា៎នៅស្រុកហ្នឹងដែរ។

ក៖ អូ៎បាទអ៊ុំបាទចុះអ៊ុំគិតថាអ៊ុំមករស់នៅហ្នឹងតាំងពីកើតម៉ងណោះអ៊ុំណោះ?

ខ៖ ចា៎ខ្ញុំនៅតាំងពីកើត។

ក៖ អត់មានជំលាសទៅណាអត់មាននៅណាទេ?

ខ៖ ហ្នឹងហើយ!

ក៖ នៅហ្នឹងរហូត?

ខ៖ ជំលាសតែជំនាន់អាពតណុងរួចបាននេះទៅមកវិញ។

ក៖ អូ៎!

ខ៖ មកចូលស្រុកវិញ។

ក៖ បាទអ៊ុំបាទ!

ខ៖ ចាំ!

ក៖ ចឹងមានន័យថាអស់ជាងជិតហុកសិបឆ្នាំហើយណោះអ៊ុំណោះ?

ខ៖ ចាំ!

ក៖ ចុះអ៊ុំមានបងប្អូនកូនចៅកូនក្មួយណាដែរទៅរស់នៅក្រៅប្រទេសអត់អ៊ុំ ដូចនៅវៀតណាមនៅថៃធ្វើការ?

ខ៖ អត់មានទេ។

ក៖ នៅកូរ៉េអីអត់មានដែរហោស?

ខ៖ ចាំអត់មានផង។

ក៖ អូ៎ចឹងមានតែនៅខ្មែរហ្នឹងទេណោះអ៊ុំណោះ?

ខ៖ ចាំមានតែនៅខ្មែរ។

ក៖ ចុះមាននរណាគេដែរនៅឆ្ងាយពីកំពង់ចាមអត់ដូចនៅភ្នំពេញនៅសៀមរាបនៅអីកូនចៅហាសអ៊ុំ?

ខ៖ អត់មានមានតែកូនមួយនៅព្រៃវែង។

ក៖ អូ៎!

ខ៖ ចាំក្រៅហ្នឹងនៅកំពង់ចាមយើងហ្នឹងទាំងអស់គ្នា?

ខ៖ ចាំនៅខេត្តកំពង់ចាមហ្នឹងទាំងអស់គ្នា។

ក៖ អូ៎បាទអ៊ុំចុះអើប្តីរបស់អ៊ុំឈ្មោះអីគេទៅអ៊ុំ?

ខ៖ ប្តីខ្ញុំឈ្មោះកៅសុខជា។

កៈ អ៎ូប៉ុន្តែឥឡូវគាត់ធ្វើអីគេទៅអ៊ុំ?

ខៈ គាត់នៅធ្វើការកំពង់ចាម។

កៈ អ៎ូគាត់ធ្វើការនៅកំពង់ចាមហោស?

ខៈ ចា៎!

កៈ ប៉ុន្តែអ៊ុំការអស់ប៉ុន្មានឆ្នាំហើយ?

ខៈ ខ្ញុំការតាំងពីប៉ែត្រពីរមក។

កៈ ប៉ែត្រពីរទាល់ឥឡូវសាមសិបប្រាំបីឆ្នាំ?

ខៈ ចា៎!

កៈ អ៎ូយូរដោយសារតែពេលដែរអ៊ុំការហ្នឹងដូចជាអ៊ុំទំនេរពោះសិនរឺមួយក៏អ៊ុំមានកូនហើយ?

ខៈ មានប៉ុនកូនកូនបងគេងាប់បាត់ហើយហ្នឹង!

កៈ អ៎ូ!

ខៈ នៅតែកូនបន្ទាប់។

កៈ កូនបន្ទាប់ណុងអាយុប៉ុន្មានអ៊ុំ?

ខៈ សាមប៉ុន្មានសាមបួនហើយយ៉ាងឆ្នាំថោះ។

កៈ សាមបួនហោស?

ខៈ ចា៎!

កៈ អ៎ូចុះអ៊ុំគិតថាទាក់ទងពីកូនរបស់អ៊ុំវិញអ៊ុំមានកូនប៉ុន្មាននាក់ទៅ?

ខៈ ប្រាំ។

កៈ ប្រាំនាក់ប៉ុន្តែស្លាប់មួយ?

ខ៖ ចាំស្លាប់មួយទាំងអស់..។

ក៖ ប្រាំមួយ?

ខ៖ ប្រាំមួយនៅសព្វថ្ងៃប្រាំ។

ក៖ អូ៎បាទប៉ុន្តែអើគាត់ស្លាប់ស្លាប់នៅពេលណាអ៊ុំ?

ខ៖ នៅកាលអាយុបីឆ្នាំកើតកញ្ជ្រិលមើលអត់ជា។

ក៖ គាត់ស្លាប់..?

ខ៖ កាលជំនាន់ណុងមិនសូវមានពេទ្យដែរណុងកូនខ្ញុំណុងមិនសូវមានពេទ្យដែរ។

ក៖ អូ៎!

ខ៖ ងាប់តាំងពីប៉ែត្រជាងម៉េស។

ក៖ បាទអ៊ុំបាទ!

ខ៖ ប៉ែត្របីងាប់ប៉ែត្របី។

ក៖ ចុះ…?

ខ៖ ប៉ែត្របីប៉ែត្របួនប៉ែត្រប្រាំ។

ក៖ បាទអ៊ុំ!

ខ៖ បីឆ្នាំ។

ក៖ ចុះអ៊ុំគិតថាកូនទីពីរឆ្នាំថោះគាត់នៅណាអ៊ុំ?

ខ៖ នៅណោះនៅលើហោស!

ក៖ ចឹងគាត់មានគ្រួសារហើយណោះ?

ខ៖ ស្នឹងត្រង់ហោសចាំ!

ក៖ គាត់មានកូនប៉ុន្មាននាក់ទៅអ៊ុំ?

ខ៖ មានកូនបី។

ក៖ កូនបី?

ខ៖ ចាំ!

ក៖ ប៉ុន្តែគាត់ធ្វើអីគេនៅស្ទឹងត្រង់អ៊ុំ?

ខ៖ ធ្វើចំការដែរ។

ក៖ អូំ!

ខ៖ ធ្វើចំការតិចតួច។

ក៖ ចុះកូនបន្ទាប់ទៀតអ៊ុំកូនទីបី?

ខ៖ បន្ទាប់ទៀតនៅហ្នឹង!

ក៖ ប៉ុន្តែគាត់មានគ្រួសារដែរ?

ខ៖ ចាំមានគ្រួសារ។

ក៖ អូំគាត់ធ្វើអីគេនៅហ្នឹងអ៊ុំ?

ខ៖ ធ្វើស្រែចំការរកស៊ីចិញ្ចឹមត្រីចិញ្ចឹមសាច់អីតិចតួចហ្នឹង!

ក៖ អូំរួចចុះបន្ទាប់ទៀត?

ខ៖ បន្ទាប់មួយទៀតនៅព្រៃវែង។

ក៖ អូំដែរអ៊ុំថាកូននៅព្រៃវែងណុងហោស?

ខ៖ ចាំ!

ក៖ គាត់យកប្រពន្ធនៅព្រៃវែងហោស?

ខ៖ យកប្រពន្ធនៅព្រៃវែង។

ក៖ ចុះគាត់ធ្វើអីគេនៅណុងរឺមួយ..?

ខ៖ រកស៊ីផ្សារដែកផ្សារអីហ្នឹងស៊ីឈ្នួលគេផ្សារដែកផ្សារអី។

ក៖ ជាមួយប្រពន្ធកូនគាត់ហ្នឹងទៅ?

ខ៖ ចាំជាមួយប្រពន្ធកូនណុងទៅ។

ក៖ អូ៎ចុះបន្ទាប់ពៅគេអ៊ុំ?

ខ៖ នៅអាមួយទៀតនេះផ្ទះនៅទីនេះស៊ីឈ្នួលគេដែរធ្វើការសំណង់។

ក៖ ណុងក៏គាត់មានគ្រួសារដែរ?

ខ៖ ចាំរួចពៅគេហ្នឹងក៏ស៊ីឈ្នួលគេដែរធ្វើការសំណង់អីពីផ្ទះចឹងដែរ។

ក៖ អូ៎!

ខ៖ ចាំ!

ក៖ និយាយរួមកូនចៅរបស់អ៊ុំមានគ្រួសារទាំងអស់ដែរហើយ?

ខ៖ ចាំមានអស់ហើយ!

ក៖ ចឹងចៅច្រើនហាសណោះអ៊ុំណោះ?

ខ៖ ចៅដប់ប្រាំនាក់។

ក៖ អូ៎ច្រើនចុះអើអ៊ុំការហ្នឹងអ៊ុំការអស់រយះពេលប៉ុន្មានសាមសិបប្រាំបីឆ្នាំ?

ខ៖ ចាំ!

ក៖ នៅពេលដែរអ៊ុំការហ្នឹងអ៊ុំគិតថាយើងជាអ្នករៀបចំដោយខ្លួនឯងរឺមួយក៏ឪពុកម្តាយអ្នករៀបចំអោយអ៊ុំពេលណុង?

ខ៖ ឪពុកម្ដាយរៀបចំអោយពេលណុង។

ក៖ អូ៎ប៉ុន្តែយើងស្គាល់គ្នាពីមុននៅ?

ខ៖ អត់ស្គាល់ផង។

ក៖ ប្ដីអ៊ុំអ្នកនៅណា?

ខ៖ ប្ដីខ្ញុំនៅកំពង់ចាមហោសព្រៃដើមចាន់ហោស!

ក៖ អូ៎!

ខ៖ ចាំរួចទៅខ្ញុំនៅស្រុកហ្នឹង!

ក៖ ដល់ពេលគាត់មកយកអ៊ុំមកគាត់មកនៅហ្នឹង?

ខ៖ ចាំ!

ក៖ អូ៎ប៉ុន្តែកាលអ៊ុំការហ្នឹងដូចជាមានថ្លៃទឹកដោះថ្លៃជំនូនអត់អ៊ុំ?

ខ៖ មានប៉ុនមានតិចតួចជំនាន់ណុងបង្គាប់បានណាច្រើនតិចតួច។

ក៖ អូ៎បាទអ៊ុំប៉ុន្តែយើងអត់ដែរមានអនុស្សាវរីយ៍ស្គាល់គ្នាពីមុនទេអ៊ុំណោះ?

ខ៖ ចាំអត់ផង។

ក៖ អូ៎បាទអ៊ុំអ៊ុំធ្លាប់បានរៀនខ្មែរថ្នាក់ទីប៉ុន្មានដែរអ៊ុំ?

ខ៖ ថ្នាក់ទីប្រាំពីរ។

ក៖ ថ្នាក់ទីប្រាំពីរជំនាន់ដើមហោស?

ខ៖ ជំនាន់នេះហ្នឹងដាច់អាពតហើយហ្នឹង!

ក៖ តែគេរាប់បញ្ច្រាស់វិញក៏គេរាប់ដដែរ?

ខ៖ រាប់ពីថ្នាក់ទីពីរទីបីទីបួនទីប្រាំអីចឹងទៅ។

កៈ អូ៎!

ខៈ ហ្នឹងដូចឥឡូវចឹងដែរហ្នឹង!

កៈ បាទអ៊ុំបាទ!

ខៈ រាប់ដូចចឹង។

កៈ ប៉ុន្តែកាលណុងយើងធ្លាប់រៀនបារាំងអត់អ៊ុំ?

ខៈ អត់ផង។

កៈ អត់រៀនផងហោស?

ខៈ កាលណុងដូចគេមិនអោយរៀនផងអ្នកណារៀនបារាំងគេចាប់ហាស!

កៈ អូ៎បាទអ៊ុំ!

ខៈ លួចរៀនគ្រូហ្វួយនៅរអាងណុងតិចៗដែរ។

កៈ អូ៎ចុះអ៊ុំគិតថាអើកាលអ៊ុំនៅរៀនហ្នឹងអ៊ុំធ្លាប់មានមិត្តភក្តិស្និទ្ធិស្នាលដែរធំធាត់មកជាមួយគ្នាអត់អ៊ុំ?

ខៈ អើខ្ញុំមិនសូវមានមិត្តភក្តិទេគ្រាន់តែថាស្គាល់គ្នាទៅរៀនអីចឹងទៅរាប់អានគ្នានៅសាលាបើថាអោយមកផ្ទះអីចឹងមិត្តភក្តិហៅគ្នាមកលេងផ្ទះលេងសំបែងមិនសូវមានទេ។

កៈ អូ៎បាទអ៊ុំបាទ!

ខៈ ចា៎!

កៈ ប៉ុន្តែអ៊ុំធ្លាប់លក្ខណៈថាដែរមានការចងចាំជាមួយមិត្តភក្តិថាទៅដើរលេងរឺមួយក៏ទៅណាទៅណីរឺទៅរៀនទៅអីចាប់ត្រីចាប់ក្តាមអីមានតើណោះអ៊ុំ?

ខៈ អត់ដែរទេព្រោះកាលណុងខ្ញុំនៅរៀនណុង មានរករៀនផងរកលុយផងមកផ្ទះធ្វើប្រាំងចឹងទៅដាក់ទឹកប្រាំងចឹងទៅពេលទំនេរពីទឹកប្រាំងចឹងទៅទៅរកលុយចាយខ្លួនឯងហ្នឹងយកអន្សម

យកអីទៅអាំងណុង ដើមអំពិលហ្នឹងអាំងអន្សមអាំងអីទៅយកលុយចាយទៅមួយកាក់មួយមួយកាក់អីហោសពីរមួយកាក់អីកាលជំនាន់ណុងហោស!

កៈ អូ៎បាទអ៊ុំ!

ខៈ ចា៎រកលុយចាយខ្លួនឯងហ្នឹងរៀនរកលុយចាយខ្លួនឯងមិនដូចក្មេងឥឡូវទេម្ដាយរកលុយអោយទៅរៀនទេ។

កៈ បាទអ៊ុំបាទត្រូវ!

ខៈ ចា៎!

កៈ ចុះអ៊ុំគិតថាអើស្រែចំការអ៊ុំធ្លាប់ធ្វើណោះអ៊ុំណោះ?

ខៈ ចា៎!

កៈ ជាទូទៅនៅស្រែអ៊ុំធ្វើអីគេខ្លះទៅអ៊ុំ?

ខៈ ខ្ញុំធ្វើស្រែហ្នឹងសាបស្ទូងដកណុងដាក់ជីដាក់ទឹកហ្នឹងទាំងអស់ហ្នឹង!

កៈ អូ៎!

ខៈ បាញ់ថ្នាំស្មៅ។

កៈ ឥឡូវគេឈប់ស្ទូងគេសាបម្ដងណោះ?

ខៈ សាបម្ដងហើយឥឡូវហោស!

កៈ គេព្រុះហោសអូ៎ហ្នឹងហើយគេព្រុះលឿន?

ខៈ ហ្នឹងហើយគេព្រុះឥឡូវហោសប៉ុន្មានឆ្នាំហ្នឹងគេព្រុះហាសពីមុនមកសុទ្ធតែស្ទូងដក។

កៈ អូ៎បាទអ៊ុំ!

ខៈ ចា៎!

កៈ អូ៎បាទចុះអើអ៊ុំគិតថាអ៊ុំធ្លាប់ធ្វើអាជីវកម្មលក់ដូរអីអត់អ៊ុំ?

ខ៖ មាន។

ក៖ អ៊ុំ..?

ខ៖ មកខ្ញុំមានប្តីហើយខ្ញុំលក់ត្រី។

ក៖ ចឹងហោសអ៊ុំ?

ខ៖ ចាំលក់ត្រីខ្ញុំម៉ៅត្រីគេចឹងទៅតិចចិញ្ចឹមត្រីឆ្ពោរខ្ញុំទិញត្រីម៉ៅគេមួយទ្រុងចឹងទៅខ្ញុំលក់បីបួនថ្ងៃចឹងទៅចំណេញបានមួយទ្រុងបានប្រាំម៉ឺនអីចឹងទេ ក្រោកម៉ោងពីរម៉ោងបីអីចឹងទៅទៅលក់ទៅ។

ក៖ អឺ!

ខ៖ លក់រហូតដល់ផ្សារព្រៃទទឹងហោសខ្ញុំហោស!

ក៖ អូ៎ទៅបានឆ្ងាយហាសណោះអ៊ុំ?

ខ៖ ចាំខ្ញុំលក់បានឆ្ងាយរៀងឆ្ងាយបន្តិច។

ក៖ ចុះទាក់ទងពីការចិញ្ចឹមអ៊ុំធ្លាប់ចិញ្ចឹមសត្វមាន់ ទា ជ្រូក គោ ក្របីអីអត់អ៊ុំ?

ខ៖ ចិញ្ចឹមធ្លាប់តើ!

ក៖ អូ៎!

ខ៖ ចាំ!

ក៖ ចុះអើអ៊ុំភាគច្រើនអ៊ុំចិញ្ចឹមអីគេអ៊ុំពីមុន?

ខ៖ ចិញ្ចឹមមាន់ ចិញ្ចឹមគោ ចិញ្ចឹមក្របី ជ្រូកមេជ្រូកចិញ្ចឹមមេជ្រូកទៀត។

ក៖ អូ៎បាទអ៊ុំ!

ខ៖ ចាំ!

ក៖ ចុះអ៊ុំគិតថាការងារអីគេខ្លះដែរអ៊ុំធ្លាប់ធ្វើតាំងពីក្មេងអ៊ុំ?

ខ៖ ការងារអើយធ្វើស្រែក៏ធ្លាប់ធ្វើចំការក៏ធ្លាប់ធ្វើថ្នាំក៏ធ្លាប់។

ក៖ អូ៎!

ខ៖ ចា៎ហើយហ្នឹងចិញ្ចឹមជ្រូកមេជ្រូកអីនិយាយថាសព្វទាំងអស់ការងារប្រុសការងារស្រីទាំងអស់ហ្នឹង!

ក៖ ចិញ្ចឹមត្រីចិញ្ចឹមអីហ្នឹងហោសអ៊ំណេះ?

ខ៖ ចា៎ទាំងអស់។

ក៖ អូ៎ចុះម៉េចបានអ៊ំឈប់ចិញ្ចឹមអ៊ំ?

ខ៖ ចាស់ហើយ!

ក៖ អូ៎ប៉ុន្តែកូនៗគាត់ធ្វើទៅ?

ខ៖ ចា៎នៅកូនៗរកស៊ីធ្វើតាមក្រោយទៅខ្ញុំចាស់ហើយ!

ក៖ អូ៎បាទអ៊ំបាទ!

ខ៖ ចា៎!

ក៖ ចុះអ៊ំគិតថាជីវិតរបស់អ៊ំមានការផ្លាស់ប្តូរអីគេខ្លះទៅអ៊ំតាំងពីក្មេងរហូទមកដល់ឥឡូវ?

ខ៖ អើយមើលទៅដូចគ្មានការផ្លាស់ប្តូរអីទេពិបាកនៅតែពិបាករហូតចឹង។

ក៖ អូ៎!

ខ៖ ចា៎!

ក៖ កាលអ៊ំនៅជាមួយឪពុកម្តាយរហូតដល់អ៊ំមកនៅឥឡូវ?

ខ៖ កាលនៅជាមួយឪពុកម្តាយចូលជំនាន់អាពតហើយ!

ក៖ អូ៎!

ខ៖ ពិបាកដល់ពេលយើងដាច់ពីអាពតមកយើងរកស៊ីហ្នឹងមានរបបតិចតួចហ្នឹងរកស៊ីមិនគ្រប់មិនគ្រាន់ហ្នឹងដើរស៊ីឈ្នួលគេដកស្ទូងគេអីចឹងទៅក៏នៅតែពិបាកឡូវ..?

ក៖ នៅរៀងពិបាក?

ខ៖ នៅតែពិបាកទៀតរួចយើងអត់មានមុខរបរអីរកស៊ីជួញដូរធំដុំការងារយើងបន្តិចបន្តួចហ្នឹងធ្វើស្រែបាននៅសល់ស្រូវគ្រាន់ម៉ាហូបៗចឹងទៅ។

ក៖ អូ៎បាទ!

ខ៖ ចា៎អត់មានបាននៅសល់លុយសល់កាក់អីគ្រាន់ហ្នឹងដោះស្រាយជីវភាពរាល់ថ្ងៃទៀតទេអត់មានទេមានតែដើរស៊ីឈ្នួលគេយកមកដោះស្រាយជីវភាពទៅទិញម្ហូបទិញអីហូបចឹងទៅ។

ក៖ អូ៎!

ខ៖ មានតែអង្ករទេបើថាម្ហូបរកលុយក្រៅទៀតចឹងហាស!

ក៖ ចុះកូនចៅយើងយើងនៅជាមួយកូនទីប៉ុន្មានអ៊ំ?

ខ៖ នៅជាមួយកូនអីណាខ្ញុំនៅដោយខ្លួនដែរហ្នឹង!

ក៖ ចឹងហោស?

ខ៖ ចា៎!

ក៖ អ៊ំនៅពីរនាក់តាយាយហោស?

ខ៖ នៅជាមួយតាយាយនៅជាមួយកូនក៏ប៉ុន្តែស៊ីដោយខ្លួនកូនគេស៊ីផ្សេងយើងស៊ីផ្សេងរកស៊ីដោយខ្លួនព្រោះកូនគេមានប្ដីមានប្រពន្ធហើយណាស់។

ក៖ អូ៎!

ខ៖ ចា៎!

ក៖ ពួកគាត់បែកអស់ហើយហោស?

ខ៖ ចាំគេបែកអស់ហើយ!

ក៖ អូ៎ប៉ុន្តែពួកគាត់អត់នៅឆ្ងាយណាហីនៅម្តុំៗអ៊ំតើហី?

ខ៖ នៅហ្នឹងនៅក្បែរៗហ្នឹងដែរ។

ក៖ អូ៎បាទអ៊ុំបាទចុះអ៊ុំគិតថាម្ហូបអីដែរអ៊ុំចូលចិត្តហូបអ៊ុំ?

ខ៖ អើធម្មតាក្មួយអើយម្ហូបអីក៏ខ្ញុំហូបកើតដែរប៉ុន្តែនៅស្រុកនេះមិនសូវបានឆ្ងាញ់ទេច្រើនតែប្រហុកផ្អកប្រហុកផ្អកណុងហើយត្រីសាច់តូចតាចណុងហើយស្លម្ជូរទៅប្រហើរទៅ។

ក៖ អូ៎!

ខ៖ ចឹងទៅទេ។

ក៖ បាទអ៊ុំបាទ!

ខ៖ ព្រោះយើងរកលុយមិនបានយើងទៅរកអីបានឆ្ងាញ់។

ក៖ ត្រូវអ៊ុំត្រូវ!

ខ៖ ចាំ!

ក៖ រួចចុះអ៊ុំគិតថាកាលពីក្មេងអ៊ុំធ្លាប់លេងល្បែងប្រជាប្រិយ៍អីអត់អ៊ុំលក្ខណៈដូចបោះអង្គុញ ចោលឈូង លាក់កន្សែង ទាញព្រាត់អីហាស?

ខ៖ ខ្ញុំមិនសូវដែរទៅលេងហ្នឹងគេផង។

ក៖ អើម៉េចចឹងអ៊ុំ?

ខ៖ មិនសូវដែរទៅលេងព្រោះផ្ទះយើងនៅឆ្ងាយពីគេចឹងស្ងាត់អីចឹងហាស ខែចូលឆ្នាំអីចឹងមិនសូវទៅទេព្រោះវាស្ងាត់ខ្លាច។

ក៖ បាទអ៊ុំបាទ!

ខ៖ ចាំ!

កៈ ប៉ុន្តែកាលពីមុនអ៊ុំនៅហ្នឹងដែរណេះអ៊ុំណេះ?

ខៈ នៅហ្នឹងដែរ។

កៈ ប៉ុន្តែអត់សូវមានផ្ទះមានសំបែងអីណេះអ៊ុំណេះ?

ខៈ ផ្ទះមានតែមួយពីរចឹងហាសតឡូរច្រើនហ្នឹងហាសកាលមុនស្ងាត់។

កៈ អូ៎!

ខៈ តាមនេះអីព្រៃណុងផ្លូវតូចព្រៃដើរ។

កៈ អូ៎!

ខៈ ចា៎!

កៈ រួចចុះអ៊ុំគិតថាអើរាំច្រៀងអីអ៊ុំចូលចិត្តណេះអ៊ុំ?

ខៈ ខ្ញុំអត់ចេះរាំចេះច្រៀងទាំងអស់គ្រាន់តែថាទៅមើលគេទៅ។

កៈ អូ៎!

ខៈ មើលទៅមើលទៅឃើញគេលេងដូចថាគេការគេអីចឹងទៅគេមានអកកណ្តុងអីចឹងគេរាំគេច្រៀងអីទៅមើលគេចឹងទៅ បើថាអោយទៅរាំទៅច្រៀងអីហ្នឹងគេទៅរាំអីរាំមិនចេះសោះហើយ!

កៈ បាទអ៊ុំបាទ!

ខៈ ចា៎អារឿងខាងហោសគេផឹកគេស៊ីអីគេផឹកស្រាអីចឹងអីតែគេហៅផឹកក៏មិនចេះដែរ។

កៈ អូ៎!

ខៈ មិនចេះទេ។

កៈ បាទអ៊ុំបាទចុះអ៊ុំគិតថាអើទាក់ទងពីល្ខោនយីកេអាយ៉ៃអីអ៊ុំចូលចិត្តទេ?

ខៈ មិនសូវចូលចិត្តទេខ្ញុំទៅមើលល្ខោនទៅតែមើលគេតិចចឹងទៅមកផ្ទះវិញ។

កៈ អុំ!

ខៈ ចាំ!

កៈ បាទអ៊ុំបាទរួចចុះធិមអីឥឡូវអ៊ុំនៅសុំសិល្បីមែន?

ខៈ អត់ទាន់សុំសិល្បីទេប៉ុនខ្ញុំចេះធិមខ្ញុំរៀនចឹងទៅខ្ញុំចេះខ្លះៗចឹងដែរ។

កៈ អុំ!

ខៈ ចាំ!

កៈ បាទអ៊ុំបាទចុះ..?

ខៈ សុំសិល្បីអីណាបើពោះនៅឃ្លានទៅសុំសិល្បីបានអីហូបក្មួយនៅរកតិចសិន។

កៈ អុំទាល់ចាំមើលយើងរៀងធូរតិចសិនណោះអ៊ុំណោះ?

ខៈ ចាំ!

កៈ ចុះអ៊ុំគិតថាអើអ៊ុំមានបងប្អូនកូនចៅណាដែរចេះលេងឧបករណ៍ភ្លេងអត់អ៊ុំ?

ខៈ មានតែឪពុកមាប៉ុនគាត់ខូចហើយគាត់ចេះភ្លេងខ្មែរ។

កៈ អុំ!

ខៈ ចាំ!

កៈ ភ្លេងសៀមពិនពៀតអីអត់មាននរណាអីទឪតចេះទេណោះអ៊ុំណោះ?

ខៈ អត់ទេ។

កៈ គាត់អត់មានបង្រៀនទៅកូនចៅផង?

ខៈ អត់ផង។

កៈ អុំបាទអ៊ុំចុះអ៊ុំគិតថាអើផ្ទះរបស់កាលអ៊ុំនៅជាមួយឪពុកម្ដាយផ្ទះម៉េចអ៊ុំ?

ខ៖ ផ្ទះតូច។

ក៖ ផ្ទះតូចណោះអ៊ុំណោះ?

ខ៖ ចាំឥឡូវក៏នៅតែតូចដដែរមិនធំបានធំផង។

ក៖ អូ៎!

ខ៖ ចាំ!

ក៖ អត់ទាន់មានផ្ទះធំនៅទេណោះអ៊ុំណោះ?

ខ៖ ចាំអត់មានផ្ទះធំនៅផង។

ក៖ ចុះនៅពេលដែរអ៊ុំចាប់ដៃជាមួយប្តីប្រពន្ធផ្ទះអ៊ុំម៉េចទៅ?

ខ៖ ចាប់ដៃជាមួយប្តីប្រពន្ធផ្ទះខ្ញុំតូចដែរហ្នឹងធ្វើផ្ទះតូចហោស!

ក៖ និយាយ..?

ខ៖ ដល់ពេល...។

ក៖ លក្ខណៈផ្ទះឈើណោះអ៊ុំ?

ខ៖ ចាំកូនឈើដល់ពេលយើងមានកូនមានចៅទៅកូនហ្នឹងវាចេះតែឈឺពេកចឹងទៅដល់ពេលកូនធំៗទៅយើងក៏រកវាមិនសូវបានចឹងកូនវាធំៗទៅវារកមិនសូវបានវាជួយយើងគ្រាន់ម៉ាគ្រប់គ្រាន់ៗហ្នឹង!

ក៖ បាទអ៊ុំបាទ!

ខ៖ ទៅពេលវាអាយុច្រើនៗហោសម្នាក់អាខ្លះសាមអាខ្លះអីចឹងទៅវាយកប្តីយកប្រពន្ធអស់ទៅ។

ក៖ អូ៎!

ខ៖ ចាំ!

កៈ ចឹងនៅពេលដែរពួកគាត់គ្រប់អាយុពួកគាត់យកប្ដីប្រពន្ធទៅគាត់អស់ពេលជួយយើងហើយណេះ?

ខៈ ចាំអស់ពេលជួយហើយណាស់យើងតែពីរនាក់ប្ដីប្រពន្ធហ្នឹងរកទៅ។

កៈ អូ៎!

ខៈ ចាំ!

កៈ ចុះឥឡូវយើងរកអីទៅអ៊ុំអើកូនចៅអត់នៅក្បែរយើងផង?

ខៈ ខ្ញុំធ្វើចំការដែរហ្នឹងខ្ញុំធ្វើប្រាំងទៅខ្ញុំដាំឈូកអីចឹងទៅខែរដូវហាស!

កៈ ឥឡូវហោសអ៊ុំ?

ខៈ ចាំ!

កៈ ចុះប្ដីអ៊ុំ?

ខៈ ប្ដីខ្ញុំទៅធ្វើការស៊ីឈ្នួលគេដែរ។

កៈ នៅកំពង់ចាមហ្នឹង?

ខៈ ចាំ!

កៈ ឥឡូវគាត់ទៅបាត់ហើយ?

ខៈ ទៅហើយ!

កៈ អូ៎គាត់ធ្វើអីគេអ៊ុំធ្វើសំណង់មែន?

ខៈ ចាំ!

កៈ អូ៎បាទអ៊ុំបាទចុះទាក់ទងពីអ៊ុំមានបងប្អូនរឺមួយក៏មិត្តភក្ដិកូនចៅណាដែរចេះធ្វើផ្ទះអត់អ៊ុំ?

ខៈ មានបងថ្លៃចេះធ្វើផ្ទះក្បឿង។

កៈ អុំ!

ខៈ ចាំ!

កៈ ប៉ុន្តែកូនចៅអ៊ុំអីអត់ចេះទេណោះអ៊ុំណោះ?

ខៈ ធ្វើដែរវាដើរស៊ីឈ្នួលជាមួយឪពុកធំណុងធ្វើផ្ទះដែរ។

កៈ អុំ!

ខៈ ចាំ!

កៈ បាទអ៊ុំបាទអ៊ុំគិតថាឪពុកម្តាយគាត់ធ្លាប់បង្រៀនពីជំនាញអីមួយទៅអ៊ុំអត់?

ខៈ អើយម៉ែឪខ្ញុំគាត់មិនចេះធ្វើអីផងហោសគាត់ធ្វើតែប្រាំងធ្វើស្រែធ្វើតែប្រាំងបង្រៀនតែពីស្រែពីប្រាំងហ្នឹងពីចំការហ្នឹង!

កៈ អុំ!

ខៈ ចាំ!

កៈ ចឹងអ៊ុំចេះតែអាហ្នឹងទេណោះអ៊ុំណោះ?

ខៈ ចាំ!

កៈ អុំបាទអ៊ុំបាទចុះអើចុះអ៊ុំគិតថាជីវភាពសព្វថ្ងៃម៉េចដែរអ៊ុំឥឡូវអ៊ុំពីរនាក់យាយតា?

ខៈ ជីវភាពសព្វថ្ងៃគ្រាន់បានម៉ាគ្រប់ម៉ាគ្រាន់។

កៈ ប៉ុន្តែកូនចៅអីគាត់ផ្ញើរមកអោយចាយដែរតើហីអ៊ុំ?

ខៈ កូនចៅគ្នារកមិនបានដែរគ្នាបានអីផ្ញើរអោយយើងបានវាផ្គត់ផ្គង់តែកូនចៅវាគ្រប់គ្រាន់ទៅយើងអរពេកណាស់ហើយ!

កៈ អុំ!

ខៈ ចាំ!

កៈ បាទអ៊ំបាទប៉ុន្តែចឹងអ៊ុំអត់មានយកចៅយកមកចិញ្ចឹមអីណាអត់ណាហី?

ខៈ អត់ទេមានមានចៅកំព្រាចៅកំព្រាឪពុកនៅតែម្តាយ។

កៈ មានដែរអ៊ុំហោស?

ខៈ មានចៅពីរនាក់។

កៈ នៅជាមួយអ៊ុំរាល់ថ្ងៃហោស?

ខៈ ចាំប្រុសមួយស្រីមួយ។

កៈ អូ៎បាទអ៊ុំបាទចុះចឹងអ៊ុំកាលពីក្មេងអ៊ុំធ្លាប់មានគោលបំណងថាអ៊ុំធំឡើងចង់ធ្វើអីមួយកាលអ៊ុំនៅរៀនហាសធ្លាប់គិតទេអ៊ុំ?

ខៈ មានគោលបំណងប៉ុនទៅវាមិនរួចធ្វើម៉េច។

កៈ អូ៎ម៉េចចឹងអ៊ុំ?

ខៈ បើយើងកាលពីជំនាន់ណុងមានទៅគ្រូបង្រៀនអីណាបានគ្រប់គ្រាន់ដូចយើងក្មេងឥឡូវ។

កៈ បាទអ៊ុំបាទ!

ខៈ ហើយគ្មានការងារអីធ្វើទៀត។

កៈ អូ៎!

ខៈ ចាំ!

កៈ បាទអ៊ុំបាទចុះអើអ៊ុំខ្ញុំមានសំនួរចុងក្រោយមួយ បើសិនជាចង់អោយអ៊ុំផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗហាសអ៊ុំមានពាក្យពេចន៍អីដែរចង់ទូន្មានព្រានប្រដៅទៅពួកគាត់ទេអ៊ុំ?

ខៈ ចង់ថាមានពាក្យពេចន៍ថាកូនក៏ដោយចៅក៏ដោយក្មួយក៏ដោយក្រោយៗហ្នឹងអោយតស៊ូតស៊ូដើម្បីជីវិតបើមិនតស៊ូមិនអាចជីវិតហ្នឹងបានល្អប្រសើរទេពិបាកហើយ ដូចខ្ញុំចឹងមែនថាខ្ញុំមិនតស៊ូទេខ្ញុំតស៊ូប៉ុន្តែតស៊ូកាលពីជំនាន់ណុងវាអត់មានការងារហោស យើងរៀនចឹងទៅវាខ្វះថវិកាអីចឹងទៅយើងទៅវាមិនរួចឥឡូវហ្នឹងខ្ញុំចេះតែប្រដៅចៅដែរថាចៅអើយតស៊ូរៀនអោយ

បានថ្នាក់អោយខ្ពស់ហ្នឹងគេទៅទោះតែជីដូនហ្នឹងគ្មានអាម៉េចក៏ដោយក៏ជីដូនតស៊ូអោយចៅរៀនអោយបានថ្នាក់ខ្ពស់ទៅបានធ្វើការធ្វើងារទៅវាធូរខ្លួនមើលជីដូនដឹងទៅមានទៅណារួចមានតែស្រែចំការហ្នឹងកាយដីហ្នឹងចំទិត្យក្តិចកាយដីហ្នឹង!

ក៖ អូ៎!

ខ៖ ចាំសព្វថ្ងៃហ្នឹងប្រដៅចៅចឹងរហូតខ្ញុំ..។

ក៖ អោយគាត់ខំប្រឹងរៀនណេះ?

ខ៖ ចាំអោយខំរៀនប៉ុនមិនអោយធ្វើអីទេចៅឯងខំរៀនមើលគេទៅគេតស៊ូមើលយើងមើលក្នុងទូរទស្សន៍ទៅអ្នកគេតស៊ូថាគេរបៀបម៉េច ចេះតែប្រដៅចឹងរហូតហ្នឹងចឹងខ្ញុំផ្តាំផ្ញើរចឹងប៉ុណ្ណឹង!

ក៖ អូ៎ចុះប៉ុន្តែអ៊ុំធ្លាប់អ៊ុំធ្លាប់ទូន្មានទៅពួកគាត់ថាចង់កុំអោយពួកគាត់ដើរក្នុងសង្គមដែរអត់ល្អហាស?

ខ៖ ចាំ!

ក៖ ដូចលក្ខណៈថាជក់គ្រឿងញៀន?

ខ៖ អើយអាហ្នឹងប្រដៅខ្លាំងជាងហ្នឹងទៀតដូចថាកូនមានប្តីមានប្រពន្ធហើយហ្នឹងប្រដៅកូនអើយកុំទៅជក់កុំទៅក្បែរអាគ្រឿងញៀនហ្នឹងអោយជៀសអោយឆ្ងាយ។

ក៖ បាទអ៊ុំ!

ខ៖ មែនប្រដៅតែគ្រឿងញៀនទេខ្ញុំប្រដៅដល់ស្រាទៀត។

ក៖ អូ៎!

ខ៖ ចាំប្រដៅទាំងអស់ហ្នឹងខ្ញុំហោស!

ក៖ អូ៎អ៊ុំដែរទូន្មានពួកគាត់រាល់ថ្ងៃដែរណេះអ៊ុំណេះ?

ខ៖ រាល់ថ្ងៃកូននៅក្បែរៗហ្នឹងប្រដៅរាល់ថ្ងៃអាប្រុសៗហ្នឹង!

ក៖ រួចចុះអ៊ុំមានធ្លាប់មានគោលបំណងថាធំឡើងចង់អោយពួកគាត់ធ្វើអីមួយអត់?

ខ៖ កូនខ្ញុំវានេះមានប្រពន្ធអស់ហើយតែចៅហ្នឹងមានគោលបំណងថាចង់អោយចៅហ្នឹងរៀនអោយចប់ទៅអោយបានសញ្ញាអោយបានអើដូចថាប្រលងជាប់ថ្នាក់ទីដប់ពីរហ្នឹងអោយបានបរិញ្ញាអីចឹងទៅយើង...។

ក៖ មានការងារអីល្អ?

ខ៖ មានការងារតែប្រលងជាប់ទៅយើងមានការងារទៅធ្វើការងារអីក៏បានដែរ។

ក៖ អូ៎បាទអ៊ុំ!

ខ៖ ចា៎!

ក៖ ចឹងអ៊ុំមានពាក្យពេចន៍អីដែរចង់ផ្តាំផ្ញើរផ្សេងពីហ្នឹងទៀតទេអ៊ុំ?

ខ៖ មានពាក្យពេចន៍ចង់ផ្តាំផ្ញើរថាមែនថាកូនចៅទេទាំងអស់ប្រជាជនយើងទាំងអស់ហ្នឹង នៅក្នុងប្រទេសកម្ពុជាហ្នឹងទាំងអស់ហ្នឹងទាំងប្រុសទាំងស្រីក្មេងសម័យក្រោយហ្នឹងអោយសុំកុំអោយដើរទៅចំគ្រឿងញៀនហ្នឹងសុំជៀសអោយផុត ហើយហ្នឹងជិះម៉ូតូជិះអីហ្នឹងកុំអោយភ្លើតភ្លើនទៅអីចឹងហាសខ្លាចឡានខ្លាចម៉ូតូអីចរាចរណ៍ហ្នឹង!

ក៖ អូ៎!

ខ៖ មានគ្រោះថ្នាក់ដល់ជីវិត។

ក៖ បាទអ៊ុំ!

ខ៖ ខ្ញុំមើលទៅដូចក្នុងនេះ។

ក៖ ញញើតហាសណោះអ៊ុំ?

ខ៖ ចា៎ញញើត។

ក៖ អូ៎បាទអ៊ុំបាទ!

ខ៖ ចា៎!

ក៖ ចឹងមានអីផ្សេងទៀតទេអ៊ុំ?

ខ៖ អត់មានអីផ្សេង។

ក៖ បាទអរគុណច្រើនអ៊ុំដែរបានអោយខ្ញុំជជែកជាមួយអ៊ុំទាក់ទងពីប្រវត្តិរបស់អ៊ុំហើយចឹងចុងក្រោយខ្ញុំសុំអ៊ុំការអនុញ្ញាតិទាំងការសម្ភាសមួយហ្នឹងទៅក្នុងវេបសាយរបស់សាលាដើម្បីតំកល់ទុកអោយកូនៗជាពិសេសចៅៗរបស់អ៊ុំដែរនៅជាមួយអ៊ុំចឹងហាស?

ខ៖ ចា៎!

ក៖ ទុកអោយពួកគាត់បានស្គាល់បានដឹងបានយល់អីចឹងហាសណាស់?

ខ៖ ចា៎!

ក៖ ចឹងអត់អីទេណោះអ៊ុំណោះ?

ខ៖ ចា៎!

ក៖ បាទចឹងជូនពរអ៊ុំដើម្បីអោយមានសុខភាពល្អដែរ?

ខ៖ ចា៎ៗអរគុណ។

ក៖ បាទចឹងអរគុណច្រើនអ៊ុំ។

ខ៖ ចា៎។